# រឿងព្រះបាទយត:

(ការមិនសោយសោក ជាឱសថវិសេសក្នុងលោក)

កាល កន្លងទៅហើយ មានព្រះរាជាមួយព្រះអង្គព្រះនាមធង្ក: ជាព្រះចៅក្រុងសាវត្ថី ។ ថ្ងៃមួយទ្រង់លើកទ័ពកេណ្ឌបរិវារទៅដណ្តើមយករាជសម្បត្តិក្នុង សាវត្ថី ហើយបរិវារចាប់ព្រះរាជាព្រះនាមយត: ជាម្ចាស់រាជសម្បត្តិក្រុងពារាណសីនោះ ចងដោយច្រវាក់ទាំងខ្សែ ៗ ហើយឲ្យរុញបញ្ចូលក្នុងគុកទៀត ។

ព្រះបាទយត: ស្តេចពុំសោយសោកនូវរាជសម្បត្តិ ដែលធ្លាក់ទៅក្នុងកណ្តាប់ដៃនៃបច្ចាមិត្តសោះ ទ្រង់គិតប្រមូលមកនូវកសិណ ហើយនាំឈានឲ្យកើតឡើងក៏ហោះឡើងទៅអង្គុយពែនភ្នែន នាអាកាសវេហាស៍ ។

ព្រះរាជាធង្ក: គ្រាន់តែទតឃើញហេតុនោះ ការក្តៅក្រហាយក៏កើតឡើងមួយរំពេច ទើបក្រោកទៅកាន់សំណាក់ព្រះបាទយត: ហើយមើលព្រះភក្ត្រ ព្រះបាទយត: ក៏ស្រាប់តែឃើញព្រះភក្ត្រនោះស្រស់បំព្រង ព្រមដោយសិរីដូចជាស្រទាប់ផ្កាឈូកមានសម្បុរដូចមាស ទើបសួរហេតុការណ៍ដែលមិនសោយសោកនោះ ។

ព្រះបាទយត:ទ្រង់ក៏ពោលនូវគាថា ដែលមានក្នុងធង្ករាជជាតកប្រាប់ស្តេចធង្ក: ថា

**នាព្ភតីតហរោ សោកោ នានាគតសុខាវហោ**
**តស្មា ធង្ក ន សោចាមិ នត្ថិសោកេ ទុតីយតា**
**សោចំ បណ្ឌុកិសោ ហោតិភត្តញ្ចាស្ស ន រុច្ចតិ**
**អមិត្តា សុមនា ហោន្តិ សល្លវិទ្ធស្ស រុប្បតោ ។**

សេចក្តីសោកមិនមែននាំមកនូវសម្បត្តិដែលកន្លងទៅហើយទាំងមិននាំនូវ សេចក្តីសុខក្នុងអនាគតផង ឯខ្ញុំក៏មិនមែនជាសំឡាញ់នឹងសេចក្តីសោកដែរ ម្នាលធង្ក: ព្រោះហេតុនោះ ទើបខ្ញុំមិនសោយសោក ។

បុគ្គលដែលសោយសោកតែងមានសិរីរ:ស្គមហើយបរិភោគបាយក៏មិនមានឪជារស ។ សត្រូវទាំងឡាយរមែងក្តៅក្រហាលចំពោះសរតី សេចក្តីសោកដែលមុត

ហើយ ទើបជាសត្វមានចិត្តល្អវិញ ។

ព្រះរាជាធង្កៈទ្រង់ព្រះសណ្តាប់គាថានោះចប់ហើយ ក៏ឲ្យព្រះបាទយតៈអត់ទោសឲ្យ ហើយប្រគល់រាជសម្បត្តិឲ្យ ទើបស្តេចត្រឡប់ទៅកាន់នគរសាវត្ថីវិញ ។ គួរឲ្យសរសើរព្រះទ័យព្រះបាទយតៈណាស់ គ្រាន់តែទ្រង់បានទទួលរាជសម្បត្តិពីស្តេចបច្ចាមិត្តហើយ ក៏ប្រគល់ឲ្យអាមាត្យទាំងឡាយ ទើបទៅបួសក្នុងហេមពាន្តប្រទេស មិនដែលមានឈានសាបសូន្យម្តងឡើយ លុះអាយុអស់ហើយក៏បានទៅកើតក្នុងព្រហ្មលោកនាយ ។

សូមអស់លោកអ្នកអនុមោទនា!

(ចប់)